Reading Book

ពិភពរឿងនិទាន

The World of Stories

រឿង កូនកង្កែបស្តាប់ជំបូន្មាន

Obedient Baby Frog



M.66

ពួកយើងទាំងអស់គ្នាត្រូវនិយាយថាទេ ! ចំពោះគ្រឿងញៀន

ការអប់រំក្នុងរឿងនេះ

ស្តាប់បង្គាប់ឪពុកម្តាយយើង មានន័យថា ការពារខ្លួនយើងឱ្យរួចផុតពីគ្រោះថ្នាក់។

ពាក្យត្រូវរៀន


សត្រូវ	គូសត្រូវ អ្នកដែលប្រឆាំងនឹងយើង
ឆ្ងាញ់	អ្វីដែលញ៉ាំហើយចង់ញ៉ាំទៀត
សម្រេច	សម្រេចចិត្តធ្វើអ្វីមួយដែលគួរធ្វើ
ធូរស្បើយ	ឈប់ព្រួយបារម្ភ
ស្តាប់បង្គាប់	ធ្វើតាមអ្វីដែលម៉ាក់ ប៉ា ឬ បងៗប្រាប់
ការពារ	ទុកឱ្យមានសុវត្ថិភាព
គ្រោះថ្នាក់	ការឈឺចាប់ដល់រូបកាយ
ស្រែកយំ	ស្រែកយំព្រោះឈឺចាប់

Morals:

Listening to our parents' advice means that we protect ourselves from danger.

Vocabulary for reading


Enemy : someone who is against or harms us
Delicious : that is pleasant to the taste and wants to eat again
Decide : to make a decision on what to do.
Relief : a feeling of happiness
Obedience : following the advice of parents or elder brothers.
Protect : To keep safe from harm or injury.
Danger : the possibility of harm to you
Groan : cried with pain.



កាលពីព្រេងនាយ មានមេកង្កែបមួយ និងកូនរបស់វា ។ មេកង្កែបស្រឡាញ់កូនរបស់វាខ្លាំងណាស់ ។ មេកង្កែបបានមើលថែកូនយ៉ាងយកចិត្តទុកដាក់ ។ ពួកគេមានសត្រូវមួយដែលតែងតែព្យាបាទ ។ សត្រូវនោះគឺជាសត្វពស់ជ័រកំណាច ។

ម្តាយកង្កែបបានប្រាប់ទៅកូនរបស់វាថា "ប្រសិនបើកូនឃើញសត្វពស់នោះ កូនត្រូវតែគេចចេញឱ្យលឿនបំផុត" ។ កូនកង្កែបឆ្លើយថា "កូនយល់ហើយណាម៉ែ" ។ បន្ទាប់មក ម្តាយកង្កែបក៏ចាកចេញពីរូងទៅរកចំណីបាត់ទៅ ។


Once upon a time, there lived a frog and her baby frog. The mother frog loved her baby very much, so she looked carefully after him.




They had an enemy who was always harmful. That enemy was a vicious snake. "If you see the snake," the mother advised her baby, "you must escape as fast as you can." "I understand, mother," replied the baby frog. Then, the mother left the hole for food.

សត្វពស់តែងតែដើររកចំណីគ្រប់ទិសទី ។ វាចូលចិត្ត
ស៊ីកង្កែបណាស់ ។ វាថា រសជាតិកង្កែបពិតជាឆ្ងាញ់មែន ។
នៅរសៀលថ្ងៃមួយ កូនកង្កែបអផ្សុកក៏ចេញមកដើរលេង
នៅខាងក្រៅ សត្វពស់បានឃើញកូនកង្កែបកំពុងដើរលេង
ក្បែរមាត់បឹងវាសប្បាយចិត្តណាស់ ។ វាក៏លូនយឺតៗទៅរក
កូនកង្កែបនោះ ។


The snake always searched for food everywhere. He liked to eat frogs very much. He said that the frog was really delicious. One day, in the afternoon, the baby frog was bored and went to play outside the hole. The snake was very happy to see the baby frog, who was going for a walk near the pond edge. He slid slowly toward the baby frog.



ពេលនោះកូនកង្កែបមានអារម្មណ៍ថា ដូចជាមានអ្នកណា
ម្នាក់កំពុងសម្លឹងមករកវាហើយ ។ ដូច្នេះវាក៏រហ័សក្រឡេក
មើលជុំវិញខ្លួនរបស់វា វាក៏បានឃើញសត្វពស់មួយកំពុង
តែសម្លឹងមករកវា ។



At that time, the baby frog felt that somebody was gazing at him. Immediately, he looked around, seeing a snake who was staring at him.




គ្រាន់តែកូនកង្កែបលោតបានពីរ-បីផ្លោតប៉ុណ្ណោះ វាក៏មកដល់ផ្ទះរបស់វាវិញ ព្រោះពេលនោះ វាក៏លេងនៅក្បែរផ្ទះរបស់វាដែរ ។



Just leaping a few steps, the baby frog got home because during that time he had played close to his home.



ទោះបីកូនកង្កែបបានចូលមកដល់ផ្ទះរបស់វាហើយក៏ដោយ ក៏វានៅតែភ័យព្រួយដដែល ព្រោះម្តាយរបស់វាមិនទាន់មកដល់ ។




Though he was in his home, he was worried because his mother was not yet in.



សត្វពស់ព្យាយាមលូនចូលទៅក្នុងផ្ទះកង្កែបដែរ ប៉ុន្តែ
មិនអាចលូនចូលទៅក្នុងរន្ធនោះបានទេ ។ ដូច្នេះវាក៏
សម្រេចចិត្តរង់ចាំនៅមាត់រន្ធកង្កែប ។

The snake tried to slither into the frog's hole, but he was unable to go inside. So he decided to wait at the hole door.






ពស់និយាយដោយសង្ឃឹមថា "អញត្រូវតែរង់ចាំកូន
កង្កែបមួយនេះ វានឹងចេញមកក្រៅក្នុងពេលឆាប់ៗនេះ" ។

"I must wait for this baby frog," the snake hopefully said. "Soon, he will come outside."






មួយសន្ទុះក្រោយមកម្តាយកង្កែបក៏មកដល់ ។ វាមានការតក់ស្លុតជាខ្លាំង នៅពេលដែលឃើញសត្វពស់ដេកនៅមុខផ្ទះរបស់វា ។ វាដឹងថា សត្វពស់មួយនេះមានបំណងចង់ស៊ីកូនរបស់វាហើយ ។ ដូច្នេះវាគិតថា វាត្រូវតែធ្វើអ្វីមួយដើម្បីជួយជីវិតកូនរបស់វា ។

A few minutes later, the mother frog arrived. She was very shocked when seeing the snake lying down in front of her home. She realized that this snake wanted to eat her baby, so she thought she would do something to save her baby's life.







រំពេចនោះវាក៏ក្រឡេកឃើញថ្មមួយដុំនៅលើដំបូលផ្ទះរបស់វា ។ វាលោតទៅឯថ្មមៗហើយរុញដុំថ្មនោះទម្លាក់ចំពីលើខ្លួនរបស់ពស់ ។ ពេលនោះសត្វពស់បានភ្ញាក់ព្រើតហើយស្រែកយ៉ាងខ្លាំង ។ សត្វពស់ស្រែកថ្ងូរដោយក្តីឈឺចាប់ "អូយ ! ឈឺណាស់ ! "រួចហើយវាក៏លូនចេញយ៉ាងលឿនបាត់ទៅ ។



Immediately, the mother frog saw a stone on the top of her home. She took little jumps and pushed the stone so as to drop onto the snake's body. At that moment, the snake was surprised and cried. "Ouch! How painful!" the snake groaned with pain and slithered away quickly.

ម្តាយកង្កែបមានអារម្មណ៍ធូរចិត្តនិងសប្បាយរីករាយ
យ៉ាងខ្លាំង ។ វាបានជួយសង្គ្រោះជីវិតកូនរបស់វាពីសត្វពស់
ហើយ ។ កូនកង្កែបត្រេកអរណាស់ ព្រោះវាបានស្តាប់តាម
បង្គាប់ម្តាយរបស់វា។ ប្រសិនបើវាមិនបានស្តាប់តាមបង្គាប់
ម្តាយរបស់វាទេ នោះវានឹងក្លាយជាចំណីរបស់សត្វពស់
បាត់ទៅហើយ ។

ចប់



The mother frog felt relief and was very happy. She had saved her baby's life from the snake. The baby frog was delighted because he had acted in obedience to his mother. If he hadn't listened to his mother's advice, he would have become the food of the snake.

The End

សំណួរ

១. តើម្តាយកង្កែបមើលថែរក្សាកូនវាដែរឬទេ?

២. តើសត្វពស់គឺជាមិត្ត ឬ ជាសត្រូវរបស់កង្កែប?

៣. ហេតុអ្វីបានជាសត្វពស់ចូលចិត្តស៊ីកង្កែប?

៤. ហេតុអ្វីបានជាសត្វពស់រង់ចាំកូនកង្កែបនៅខាងក្រៅរន្ធ?

៥. តើម្តាយកង្កែបជួយសង្គ្រោះកូនដោយវិធីណា?

Questions:

1- Did the mother frog look after her baby?

2- Was the snake a friend or an enemy of the frogs?

3- Why did the snake like to eat frogs?

4- Why did the snake wait for the baby frog outside the hole?

5- How did the mother frog save her baby?